# សុន្ទរកថា

## ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## ក្នុងសិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពជាសកលនៃការឆ្លើយតបជាពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍ ជូនអង្គការសហប្រជាជាតិ

ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤
សណ្ឋាគារ កាំបូឌីយ៉ាណា

- ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី
- លោកស្រី Marie-Odile Edmond នាយិកាអង្គការ UNAIDS ប្រចាំប្រទេសកម្ពុជា
- លោក ទឹម វ៉ា នាយកប្រតិបត្តិអង្គការ HACC ( HIV/AIDS Coordination in Cambodia)
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ថ្នាក់ដឹកនាំ តំណាងស្ថាប័នក្រសួងនៃរាជរដ្ឋាភិបាលកម្ពុជា
- លោកជំទាវ លោក លោកស្រី ជាប្រធាន តំណាងដៃគូអភិវឌ្ឍ និង សង្គមស៊ីវិល
- លោក លោកស្រី អ្នកនាងកញ្ញាជាតំណាងអ្នកផ្ទុកមេរោគអេដស៍ និងតំណាងប្រជាជនប្រឈមមុខខ្ពស់
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាសមាជិក សមាជិកាអង្គសិក្ខាសាលាទាំងអស់

ជាបឋមនេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណជាអនេកចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញចូលរួមនៅក្នុងអង្គសិក្ខាសាលាដ៏មានសារៈសំខាន់នាពេលនេះ។

ថ្ងៃនេះយើងត្រូវតែជួបជុំគ្នាប្រមាណជាជាង១០០នាក់មកពី ស្ថាប័នរាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍ សង្គមស៊ីវិល តំណាងអ្នកផ្ទុកមេរោគអេដស៍ និង អ្នកតំណាងប្រជាជនប្រឈមមុខខ្ពស់ ពិគ្រោះគ្នា បំពេញឱ្យគ្នានូវព័ត៌មាន ទិន្នន័យទាំងប្រមាណវិស័យ និង គុណវិស័យ ដើម្បីពិនិត្យ

សូចនាករទាំង៣២ និង រៀបចំរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ជូនដល់អង្គការសហប្រជាជាតិឱ្យបានតាមការកំណត់គឺថ្ងៃទី៣១ មីនា ឆ្នាំ២០១៤។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី!*

ចាប់តាំងតែពីឆ្នាំ២000ដែលសកលលោកផ្តើមកំណត់គោលដៅសហស្សវត្សរ៍ ប្រទេសកម្ពុជាយើងបានផ្ញើជូនអង្គការសហប្រជាជាតិនូវ របាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍/ជំងឺអេដស៍បែបនេះរាល់ពីរឆ្នាំម្តងអស់ចំនួនប្រាំលើកមកហើយ ។ ចុងក្រោយគឺនៅខែមីនា ឆ្នាំ២០១២កន្លងទៅ ។ ដូចនេះ គឺរាល់២ឆ្នាំម្តងអង្គការសហប្រជាជាតិមានបំណងនឹងតាមដានវឌ្ឍនភាពនៃបណ្តាប្រទេសដែលជាសមាជិកទាំងអស់ក្នុងការងារដ៏សំខាន់នេះ។

ក្នុងអំឡុងឆ្នាំ២០១២ និង ២០១៣ ប្រទេសកម្ពុជាយើងបានប្រើប្រាស់ថវិកាអស់ប្រមាណ១០០លានដុល្លាសម្រាប់អនុវត្តសកម្មភាព គម្រោងកម្មវិធី និងអន្តរាគមន៍នានា ទាំងក្នុងវិស័យសុខាភិបាល និងវិស័យនានា ដើម្បីឈានទៅសម្រេចនូវគោលដៅសូន្យបីឱ្យបានជាស្ថាពរ។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីបានជ្រាបហើយថា ទិន្នន័យគឺជាពិន្ទុ ។ ទិន្នន័យគឺជាការវាយតម្លៃ ។ ទិន្នន័យគឺជាលទ្ធផល ។ តាមរយ :ទិន្នន័យគេអាចទាញសេចក្តីសន្និដ្ឋានដើម្បីធ្វើការកែលម្អកម្មវិធីដែលបានអនុវត្តកន្លងទៅ ។ ប៉ុន្តែការវិនិច្ឆ័យសមស្របធ្វើទៅបានអាស្រ័យដោយការផ្តល់ព័ត៌មានគ្រប់ជ្រុងជ្រោយ នោះទើបការទាញសេចក្តីសន្និដ្ឋាន និងការសម្រេចចិត្តអាចប្រព្រឹត្តទៅសមស្របនឹងមានប្រសិទ្ធភាព ។ ជាឧទាហរណ៍ ដំរីមិនមែនគ្រាន់តែជាសសរបួន ឬជាអំបោស ឬក៏ជាផ្លិតនោះទេ ។ **ដំរីទាំងមូលទើបមានលក្ខណគ្រប់ជ្រុងជ្រោយ ។ ដូចនេះទិន្នន័យគឺជាអំណាច (Data is Power)** ។ អាស្រ័យហេតុនេះសូម ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងមកពីស្ថាប័នរាជរដ្ឋាភិបាល សង្គមស៊ីវិល តំណាងអ្នកផ្ទុកមេរោគអេដស៍ និង អ្នកតំណាងប្រជាជនប្រឈមមុខខ្ពស់ធ្វើការពិភាក្សា ផ្លាស់ប្តូយោបល់ដើម្បីផ្តល់សុពលភាពដល់ទិន្នន័យ និង ព័ត៌មានដែលប្រមូលបានតាមរយ:ការស្រាវជ្រាវឯកសារយោង និង ការចុះស្រង់មតិយោបល់ផ្ទាល់ពីអ្នកទទួលសេវាក៏ដូចជាអ្នកប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ផងដែរ។

ខ្ញុំសូមឆ្លៀតឱកាសជម្រាបជូនអង្គប្រជុំថា យើងមានក្រុមការងារផែនការយុទ្ធសាស្រ្តជាតិ ៥ក្រុម ដែលមានជាអាទិ៍ :

១. ក្រុមទី១ ទទួលបន្ទុកលើការងារបង្ការ ការព្យាបាល និង ការថែទាំបន្ត ។

២. ក្រុមទី២ ទទួលបន្ទុកការងារបង្កបរិយាកាសគាំទ្រ សិទ្ធិមនុស្ស និងគោលនយោបាយ

៣. ក្រុមទី៣ ទទួលបន្ទុកការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍

៤. ក្រុមទី៤ទទួលបន្ទុកការងារមគ្គុទ្ទេសក៏ភាព ទំនាក់ទំនង និង វិស័យអភិវឌ្ឍនានា (development synergy)

៥. ក្រុមទី៥ ទទួលបន្ទុកការតាមដាន និង វាយតម្លៃ

ដើម្បីឈានទៅសម្រេចគោលដៅបីសូន្យ គឺ "**គ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់** " ក្រុមទាំងប្រាំនឹងយកគោលនយោបាយទាំង៧ចំណុច របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ទៅជាការចង្អុលទិសដល់កម្មវិធីឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍តាមក្រុមគោលដៅនិងតាមដែនទទួលខុសត្រូវរបស់ខ្លួន។

ក្នុងបណ្តាក្រុមទាំងប្រាំ ក្រុមទី១ គ្របដណ្តប់លើសូចនាករ២៥ លើសូចនាករសរុបចំនួន៣២ ។ ប៉ុន្តែទោះជាយ៉ាងណាក្តី អង្គសិក្ខាសាលានឹងរៀបចំការបែងចែកក្រុមពិភាក្សាតាមគោលដៅ ទាំង១០ របស់អង្គការសហប្រជាជាតិ ដើម្បីពិនិត្យជាលម្អិត តាមគោលដៅនីមួយៗ និងរៀបចំក្រុមពិភាក្សាដោយឡែករបស់តំណាងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីទទួលព័ត៌មានគុណវិស័យ (qualitative) លើសំណុំឯកសារជាង៣០ទំព័រ ដែលហៅថា NCPI Part A (National Commitment Policy Instrument)។ ចំណែកតំណាងសង្គមស៊ីវិល អ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះក៏ត្រូវចូលរួមផ្តល់ព័ត៌មានបែបគុណវិស័យ លើសំណុំឯកសារ NCPI Part B ដែលស្រដៀង គ្នានឹង Part A ផងដែរ។

ខ្ញុំយល់ឃើញថា ក្នុងកិច្ចពិភាក្សាយើងនឹងអាចឃើញមានគម្លាតរវាងមតិយោបល់នៃអ្នកចូលរួមទាំងអស់ដែលអញ្ជើញមកពីមូលដ្ឋានផ្សេងៗគ្នា ឬជំនាញផ្សេងៗគ្នា លើទិន្នន័យ និងព័ត៌មានដែលយើងទទួលបានតាមលំដាប់សូចនាករទាំង៣២ ។ ត្រង់នេះខ្ញុំសូមឆ្លៀតឱកាសរំឭកឯកឧត្តម លោកជំទាវ លោក លោកស្រីមេត្តាផ្តល់លទ្ធភាពជូនដល់តំណាងអ្នកផ្ទុកមេរោគអេដស៍ និងតំណាងប្រជាជនប្រឈមមុខខ្ពស់ជម្រាបជូនយើងនូវស្ថានភាពផ្ទាល់នៅមូលដ្ឋាន ទាំងការទទួលសេវាបង្ការទាំងសេវាព្យាបាល និង ថែទាំក៏ដូចជាសេវាការគាំទ្រសង្គមផងដែរ ។

ខ្ញុំសង្ឃឹមថាព័ត៌មាន ទិន្នន័យដែលពាក់ព័ន្ធដែលអាចថារសើបនឹងត្រូវបានពិនិត្យ វិភាគវាយតម្លៃ និងទាញការសន្និដ្ឋានប្រកបដោយការថ្លឹងថ្លែង និង សុភវិនិច្ឆ័យព្រោះយើងយល់ច្បាស់ថាការឯកភាពជាតិ ជាសម្លេងជាតិតែមួយជាចំណុចខ្លាំងដែលគ្មានអ្វីអាចជំនួសបានឡើយ ។ នោះមិនមានន័យថាយើងគាំទ្រ និង អត់ឱនដល់អ្នកដែលសាងកំហុសឡើយ ។ ទាំងនេះគឺជាការពង្រឹងអភិបាលកិច្ចល្អដោយគណនេយ្យភាពទ្វេទិសមិនមែនតែរវាងអ្នកផ្តល់និងអ្នកទទួលហិរញ្ញប្បទានប៉ុណ្ណោះទេតែក៏ជាគណនេយ្យភាពទ្វេទិសរវាងអ្នករៀបចំគោលនយោបាយ និង កម្មវិធី និង អ្នកទទួលផលចំណេញចុងក្រោយរបស់កម្មវិធីផ្ទាល់តែម្តង។

ខ្ញុំសង្ឃឹមយ៉ាងមាំថាតាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ថ្ងៃនេះឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ទាំងស្ថាប័នរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍទាំងអស់ដែលជាតំណាងអ្នកធ្វើការងារអេដស៍ទាំង៥ពាន់នាក់ និង ផ្តល់នូវធាតុចូលដ៏មានសារសំខាន់ដើម្បី រួមចំណែកបញ្ចៀសសោកនាដកម្មនៃជំងឺដ៏មហាប្រល័យដែលយ៉ាងហោចណាស់ក្នុង១ថ្ងៃៗក៏មានប្រជាជនកម្ពុជា៦នាក់បានស្លាប់ដោយ មេរោគអេដស៍ និងមាន៣នាក់បានបន្តឆ្លងមេរោគអេដស៍។

ខ្ញុំសូមថ្លែងអំណរគុណចំពោះការប្រឹងប្រែងយ៉ាងខ្លាំងក្លាពីសំណាក់ក្រុមទីប្រឹក្សាទាំងអស់ដែលមានឆន្ទៈ និង ការលះបង់ខ្ពស់ខិតខំបំពេញការងារដ៏ធំធេងមួយក្នុងពេលវេលាដ៏សែនតូចចង្អៀត ។ ខ្ញុំសូមអរគុណដល់នាយកដ្ឋានតាមដាន និង វាយតម្លៃ និង អង្គការ UNAIDS ប្រចាំប្រទេសកម្ពុជាដែលបានសហការយ៉ាងជិតស្និទ្ធក្នុងការដ៏លំបាកនេះ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរបវរសួស្តី ជូនឯកឧត្តម លោកជំទាវ លោក លោកស្រី និង អ្នកចូលរួមទាំងអស់សូមមានសុខភាពល្អ កម្លាំងមាំមួន និងប្រាជ្ញាឈ្លៀសវៃនិងជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងសូមកោតសរសើរផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ នៃគណៈកម្មការរៀបចំអង្គពិធី និង ម្ចាស់មូលនិធិសកល ដែលបានរួមចំណែកគាំទ្រដល់ការរៀបចំសិក្ខាសាលាដ៏មានសារសំខាន់នាថ្ងៃនេះ ។ ខ្ញុំសូមប្រកាសបើកសិក្ខាសាលាផ្សៀងផ្ទាត់ របាយការណ៍វឌ្ឍនភាពជាសកលនៃការឆ្លើយតបជាពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ជូនអង្គការសហប្រជាជាតិចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*